# ឯកឧត្តមទេសរដ្ឋមន្ត្រី អញ្ជើញចូលរួមសន្និសីទអាស៊ានបូក៣ នៃរដ្ឋមន្ត្រីទទួលបន្ទុកវិស័យទឹកស្អាតនិងកម្មវិធីសប្តាហ៍ទឹកអន្តរជាតិសិង្ហបុរី ឆ្នាំ២០១៦




ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានដឹកនាំប្រតិភូក្រសួង ចូលរួមសន្និសីទអាស៊ានបូកបី នៃរដ្ឋមន្ត្រីទទួលបន្ទុកវិស័យទឹកស្អាត (ASEAN Plus Three Water Minister Forum-APTWMF) ព្រមទាំងចូលរួមសប្តាហ៍ទឹកអន្តរជាតិសិង្ហបុរីឆ្នាំ២០១៦ (Singapore International Water Week-SIWW 2016) និងកិច្ចប្រជុំកំពូលនៃថ្នាក់ដឹកនាំវិស័យទឹកស្អាត (Water Leaders Submit) ចាប់ពីថ្ងៃទី១០ ដល់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៦ នៅប្រទេសសិង្ហបុរី។ ទន្ទឹមនឹងនេះ ក៏មានកិច្ចប្រជុំកំពូលស្តីពីបរិស្ថានស្អាត (Clean Environment Summit) និងកិច្ចប្រជុំកំពូលស្តីពីទីក្រុងក្នុងពិភពលោក (World Cities Summit) ផងដែរ។ ព្រឹត្តិការនេះបានចាប់ផ្តើមជាផ្លូវការ

ដោយពិធីបើកដ៏អធិកអធម ក្រោមអធិបតីភាពរបស់ ឯកឧត្តម Tony Tan Keng Yam ប្រធានាធិបតីនៃប្រទេសសិង្ហបុរី។

សន្និសីទអាស៊ានបូកបី នៃរដ្ឋមន្ត្រីទទួលបន្ទុក វិស័យទឹកស្អាត បានផ្តោតសំខាន់លើការពិភាក្សាអំពីប្រធានបទ ការធ្វើឱ្យប្រសើរឡើង នៃនិរន្តភាព និងការ សម្របទៅនឹងអាកាសធាតុក្នុងវិស័យទឹកស្អាត និងអនាម័យ Enhancing Sustainability and Building Climate Resilience in Water Supply and Sanitation ដែលមានការចូលរួមពីបណ្តារដ្ឋមន្ត្រីនៃប្រទេសសមាជិកអាស៊ានតំណាងរបស់ប្រទេសបូកបី(ចិន ជប៉ុន និងកូរ៉េ) ព្រមទាំងមានការ ចូល រួមរបស់ដៃគូរអភិវឌ្ឍរួមមាន ធនាគារអភិវឌ្ឍអាស៊ី ធនាគារពិភពលោក និងក្រុមប្រឹក្សាទឹកពិភពលោក (World Water Council)។ ក្នុងសន្និសីទនេះ រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជាក់យ៉ាងច្បាស់អំពីបញ្ហាប្រឈមរបស់កម្ពុជាក្នុងវិស័យទឹកស្អាត ដែលត្រូវឆ្លើយតបឱ្យបានតាមតម្រូវការនៃការរីកចំរើន យ៉ាងឆាប់រហ័សនៃបណ្តាទីក្រុង និងទីប្រជុំជននានានៅទូទាំងប្រទេស ព្រមទាំងផលប៉ះពាល់នានាដែលកើតមានដោយសារការប្រែប្រួលអាកាសធាតុ ដូចជាគ្រោះមហន្តរាយ រួមមានគ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់ ជាដើម។ ក្រៅពីនេះកង្វះទឹកស្អាតប្រើប្រាស់ ក៏បានបង្កឱ្យមានជំងឺចំនួន៦ ក្នុងចំណោមជំងឺទាំង១០មុខ ដែលកើតមានច្រើនជាងគេផងដែរ។ ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះ ក្នុងអណត្តិទី៥ នៃរាជរដ្ឋាភិបាលកម្ពុជា ក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានធ្វើកំណែទម្រង់ស៊ីជម្រៅក្នុងវិស័យទឹកស្អាត ដើម្បីធានាថាកម្ពុជានឹងសម្រេចបានផែនការយុទ្ធសាស្រ្តជាតិដែលកំណត់ថាប្រជាជននៅតាមទីប្រជុំជននៅទូទាំងប្រទេសនឹងទទួលបានសេវាទឹកស្អាត១០០% នៅត្រឹមបំណាច់ឆ្នាំ២០២៥។ កំណែទម្រង់របស់រាជរដ្ឋាភិបាល បានផ្តោតទៅលើយន្តការសំខាន់ៗរួមមាន

១-លើកទឹកចិត្តឱ្យមានការវិនិយោគរបស់វិស័យឯកជនក្នុងវិស័យទឹកស្អាត ដោយបានពន្យារអាយុកាលអាជ្ញាប័ណ្ណធ្វើអាជីវកម្មទឹកស្អាត ពី៣ឆ្នាំ ទៅ២០ឆ្នាំ

២-បានចេញប្រកាសស្តីពីការកំណត់ថ្លៃលក់ទឹកស្អាត ដែលធានាបាននូវសមភាពរវាងអ្នកផ្តល់សេវា និងអ្នកទទួលសេវាទឹកស្អាត

៣-កំពុងរៀបចំពង្រាងច្បាប់ទឹកស្អាតដែលនឹងធានាឱ្យបាននូវសុវត្ថិភាព និងនិរន្តរភាពនៃការផ្គត់ផ្គង់ទឹកស្អាត ព្រមទាំងធានានូវសមភាពសម្រាប់គ្រប់ភាគីពាក់ព័ន្ធទាំងអស់

៤-ការជួយគាំទ្រយ៉ាងសកម្មទាំងផ្នែកបច្ចេកទេស និងការគ្រប់គ្រង ដល់អ្នកផ្តល់សេវាទឹកស្អាតទាំងរដ្ឋ និងឯកជន ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពនៃប្រតិបត្តិការផលិត និងចែកចាយទឹកស្អាត

៥-ការបង្កើតឱ្យមានមន្ទីរពិសោធន៍ចល័ត ដើម្បីធានាពីគុណភាព និងសុវត្ថិភាព នៃការផ្តល់សេវាទឹកស្អាតជូនប្រជាពលរដ្ឋ ។ល។ ម្យ៉ាងវិញទៀត ការគ្រប់គ្រង និងប្រើប្រាស់ប្រភពទឹកឱ្យបានសមស្រប និងមានប្រសិទ្ធភាពខ្ពស់ ក៏ជាកត្តាស្លាប់រស់ផងដែរ ដែលទាមទារឱ្យមានកិច្ចសហការណ៍ជាចាំបាច់រវាងបណ្តាក្រសួង និងស្ថាប័ន ដែលពាក់ព័ន្ធទាំងអស់ រួមមានក្រសួងធនធានទឹក និងឧត្តុនិយម ក្រសួងកសិកម្ម ក្រសួងអភិវឌ្ឍជនបទ ក្រសួងសាធារណៈការ និងក្រសួងបរិស្ថាន ជាដើម។ ទន្ទឹមនឹងនោះ រដ្ឋាភិបាលក៏បានបញ្ជាក់ផងដែរថា ការគាំទ្រផ្នែកហិរញ្ញវត្ថុរបស់បណ្តាប្រទេសបូកបី និងដៃគូអភិវឌ្ឍនានាក៏ដូចជាពីបណ្តាប្រទេសសមាជិកអាស៊ាន ពិតជាចាំបាច់ជាចម្បងដើម្បីជម្រុញឱ្យប្រជាពលរដ្ឋកម្ពុជា អាចទទួលបានសេវាទឹកស្អាតតាមបំពង់បានយ៉ាងឆាប់រហ័ស។ ក្នុងកំឡុងពេលនេះដែរ ឯកឧត្តមទេសរដ្ឋមន្ត្រី ក៏បានជួបពិភាក្សាទ្វេភាគីជាមួយ ១-ឯ.ឧ រដ្ឋមន្ត្រី ក្រសួងធនធានធម្មជាតិ និងបរិស្ថាន នៃប្រទេសឡាវ ២- ឯ.ឧ រដ្ឋមន្ត្រី ក្រសួងថាមពល បច្ចេកវិទ្យាបៃតង និងទឹកស្អាត នៃប្រទេសម៉ាឡេស៊ី

៣-លោកជំទាវរដ្ឋលេខាធិការក្រសួងសុខាភិបាល និងក្រសួងបរិស្ថាន និងធនធានទឹក នៃប្រទេសសិង្ហបុរី ដោយបានផ្តោតទៅលើការងារ រួមមាន
-ការចែករំលែកបទពិសោធន៍ក្នុងវិស័យទឹកស្អាត
តាមរយៈការផ្លាស់ប្តូរអ្នកបច្ចេកទេសគ្នាទៅវិញទៅមក
-ការគាំទ្រផ្នែកបច្ចេកទេស តាមរយៈការបណ្តុះបណ្តាលធនធានមនុស្ស
-ការរួមគ្នាសហការណ៍ក្នុងការគ្រប់គ្រង និងប្រើប្រាស់ប្រភពឱ្យបានសមស្រប និងមានប្រសិទ្ធភាព ដើម្បីធានានិរន្តភាពនៃការផ្គត់ផ្គង់ទឹកស្អាត។


ASEAN Plus Three Water Ministers Forum
11 July 2016, Singapore
EXIT


EXIT




2016 SPECIAL MENTION
singapore





